# គម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣

## ករណីសិក្សា

យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រ២នៃកម្មវិធីទប់ស្កាត់បទល្មើស និងសុវត្ថិភាពសហគមន៍ គឺការលើកកំពស់សុខុមាលភាពប្រជាពលរដ្ឋ និងជំរុញឲ្យមានឥរិយាបថល្អៗ សំរាប់សង្គម តាមរយៈការផ្តល់សេវាផ្នែកសង្គម ផ្នែកសេដ្ឋកិច្ច និងអប់រំ ដោយផ្តោតជាពិសេសទៅលើក្រុមអនីតិជន និងយុវជនដែលមានឥរិយាបថអាច ពាក់ព័ន្ធទៅនឹងបទល្មើស ឬរងគ្រោះដោយសារបទល្មើស ។ ករណីសិក្សាខាងក្រោមនេះ គឺជាលទ្ធផលជាក់ស្តែងមួយ នៃការគាំទ្ររបស់គម្រោង ស៊ី.ស៊ី.ចេប តាមរយៈយុទ្ធសាស្ត្រផ្នែកសេដ្ឋកិច្ច និងអប់រំក្នុងខេត្ត បាត់ដំបង។

ធន ធវន្ត័ ជាយុវជនម្នាក់មានអាយុ ២១ឆ្នាំ ជាកូនពៅនៃគ្រួសារត្រកូលកសិករដែលមានសមាជិកសរុបចំនួន១០នាក់ ។ ក្រុមគ្រួសារ ធវន្ត័ រស់នៅក្នុងភូមិអូរគ្រៀត ឃុំគារ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ហើយ ធវន្ត័ មានបងប្រុស៤នាក់ និងបងស្រី ៣នាក់។ ធវន្ត័ បានបោះបង់ការសិក្សាថ្នាក់ទី៩ កាលពីឆ្នាំ២០០៨ ហើយដើរលេងជាមួយក្រុមក្មេងក្នុងភូមិ ដែលសហគមន៍ និងអាជ្ញាធរមូលដ្ឋានស្គាល់ថាជា ក្រុមក្មេងទំនើង ។ អ៊ុំស្រី ឆែម ស៊ីម អាយុ៦៦ឆ្នាំ ត្រូវជាម្តាយរបស់ ធវន្ត័ បានឲ្យដឹងថា ធវន្ត បានដើរលេងរហូតយប់ជ្រៅមិនចូលផ្ទះ គិតតែពីផឹកស៊ីប៉ែឡោ ចាប់មាន់របស់បងប្អូនទៅធ្វើម្ហូបក្លែម និងជួនកាលដេញវាយតប់ជាមួយក្មេងក្រុមផ្សេងរហូតដល់ផ្ទះ រត់ឡើងលើផ្ទះបិទទ្វារទៀតផង ។ គាត់បានព្យាយាមហាមប្រាម និងប្រៀនប្រដៅ ធវន្ត័ ជាច្រើនលើកមកហើយ តែមិនបានទទួលលទ្ធផលវិជ្ជមាននោះឡើយ ។ គាត់មិនមានសង្ឃឹមថាអាចកែលម្អកូនម្នាក់នេះឡើងវិញនោះទេ ។ មិនត្រឹមតែប៉ុណ្ណោះ លោក សាំង សារ៉ាត់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាល បានបញ្ជាក់ថាកាលពីដើមឆ្នាំ២០០៩ នគរបាលប៉ុស្តិ៍បានដាក់ក្រុម ធវន្ត័ ទៅក្នុងបញ្ជីគ្រប់គ្រងក្មេងទំនើងដែលត្រូវតាមដានជាប្រចាំទៀតផង។

លោក ពុធ កែវ មេឃុំគារ ស្រុកមោងឫស្សី បានឲ្យដឹងថា តាមរយៈប្រធានភូមិ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំគារ បានចង្អុលបង្ហាញពីយុវជន ធវន្ត័ ថាគួរទាក់ទាញយកមកអប់រំកែលំអ ។ ដោយមានការគាំទ្រពីអង្គការ LAC ក្រុមប្រឹក្សាឃុំគារបានសម្រេចបង្កើតគណៈកម្មការការពារកុមារនិងស្ត្រីឃុំនៅឆ្នាំ២០០៩ ហើយ ធវន្ត ក៏ត្រូវបានលួងលោមឲ្យចូលជាសមាជិកនៃគណៈកម្មការនេះ ប្រយោជន៍ទទួលបានការអប់រំផ្លូវច្បាប់ និងសីលធម៌ ។ ក្រោយមក ជួនជាមួយនឹងមានការគាំទ្រពីគម្រោងបណ្តុះបណ្តាលមុខវិជ្ជាជីវៈជួសជុលម៉ូតូតាមរយៈកម្មវិធី ទ.ប.ស.ស នោះ និងដោយមានការព្រមព្រៀង ពីសាមីខ្លួន ធវន្ត័ និងអាណាព្យាបាល ឃុំក៏បានសម្រេចចិត្តជ្រើសរើស ធវន្ត័ ឲ្យចូលរៀនវគ្គបណ្តុះបណ្តាលមុខវិជ្ជាជីវៈជួសជុលម៉ូតូនៅឆ្នាំ២០១០ ។ បច្ចុប្បន្ន ធវន្ត កំពុងហ្វឹកហាត់ជំនាញជួសជុលម៉ូតូ ជំនាញផ្សា និងក្រឡឹងនៅហាង សេង គីម (ហៅ បាន កេង)លក់គ្រឿងបន្លាស់ម៉ូតូ កង់ គោយន្តភូមិមោង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។




គណៈកម្មាធិការអភិវឌ្ឍស្រុកមោងឫស្សីបានចុះកិច្ចសន្ទនាជាមួយលោក បាន កេង អាយុ៦២ឆ្នាំ ជាមេជាង និងម្ចាស់ហាងសេង គីម (ហៅ បាន កេង)ខាងលើ ដើម្បីផ្តល់សេវាបណ្តុះបណ្តាលដោយអនុវត្តផ្ទាល់ដល់ ធវន្តអំពីជំនាញជួសជុលម៉ូតូ (សិក្សារហូតដល់ចេះ មិន



មានពេលកំណត់)ក្នុងតម្លៃ ៥០០ដុល្លាអាមេរិក តាមរយៈមូលនិធិកម្មវិធី ទ.ប.ស.ស កាលពីត្រីមាសទី៣ឆ្នាំ២០១០ ។ លោក បាន កេង បានឲ្យដឹងថា លោកមិនត្រឹមតែបង្រៀនដល់ ធវ័ន្ត អំពីរបៀបជួសជុលម៉ូតូនោះទេ លោកបានបង្រៀនដល់ ធវ័ន្តអំពីជំនាញផ្សេងៗទៀតដូចជាជំនាញផ្សាក្រឡឹងជាដើម ។ មិនត្រឹមតែប៉ុណ្ណោះ លោកបានផ្តល់អាហារ៣ពេលក្នុង១ថ្ងៃ ទឹកខ្ទែងស្នាក់នៅ និងការណែនាំជាច្រើនរៀងរាល់សប្តាហ៏ដល់ ធវ័ន្ត ហើយរហូតដល់ពេលនេះ លោកសង្កេតឃើញថា ធវ័ន្ត មានការខុសប្លែកពីមុនច្រើនដូចជា មិនដើរលេងជាមួយមិត្តភក្តិក្មេងទំនើងយប់ជ្រៅ ឈប់ជក់បារី យកចិត្តទុកដាក់រៀនសូត្រ និងទទួលខុសត្រូវចំពោះការងារ ។

អ៊ំស្រី ឌែម ស៊ឹម ជាម្តាយរបស់ ធវ័ន្តក៏បានបញ្ជាក់ថា គាត់មានសេចក្តីអរគ្មានអ្វីប្រៀបបានទេ ក្នុងមួយជីវិតនេះ ដោយឃើញកូនរបស់គាត់ មានការកែប្រែទៅជាមនុស្សល្អយ៉ាងដូច្នេះ ។ អ៊ំស្រី ថែមទាំងបញ្ជាក់ទាំងទឹកមុខរីករាយថា ពេលធវ័ន្ត មកផ្ទះម្តងៗ វាចេះជួយការងារផ្ទះ មិនផឹកស៊ីដើរលេង ទោះជាមិត្តភក្តិបបួលក៏ដោយ ហើយថែមទាំងនិយាយស្តីមានការគួរសមទៀតផង ។ គាត់ពិតជាមិនដែលគិតថា កូនរបស់គាត់ម្នាក់នេះ អាចផ្លាស់ប្តូរយ៉ាងដូច្នេះនោះទេ ។ អ៊ំស្រី ចាប ថាវ ដែលជាអ្នកជិតខាង រស់នៅក្នុងភូមិតាំងពីឆ្នាំ ១៩៧៩ ក៏បានលើកឡើងថា ធវ័ន្ត ពិតជាបានផ្លាស់ប្តូរជាក្មេងល្អ ខុសពីមុនទាំងស្រុងមែន ។ ចំពោះ ធវ័ន្ត វិញ បានឲ្យដឹងថា ខ្លួនគេមិនបានដើរលេងជាមួយមិត្តភក្តិចាស់ទៀតទេ ដោយសារម៉្យាងខ្លាចចិត្តម្ចាស់ហាង និងម៉្យាងទៀត ក្រុមជាងដែលរួមការងារជាមួយគ្នាក្នុងហាង មិនមាននរណាដើរលេងផឹកស៊ីរហេតរហូតនោះឡើយ ។ ម៉្យាងវិញទៀត ធវ័ន្ត ថែមទាំងនិយាយថា បច្ចុប្បន្ននេះ អ្នកភូមិភាគច្រើនមានឥរិយាបថរួសរាយចំពោះខ្លួនជាងមុន មិនដូចកាលពីខ្លួននៅសេពគប់ជាមួយក្រុមក្មេងទំនើងនោះឡើយ ។ លើសពីនេះ ធវ័ន្ត បានលើកឡើងថា ខ្លួនគេមានបំណងបើកពេងជាងជួសជុលម៉ូតូផ្ទាល់ខ្លួន នៅពេលបញ្ចប់ការរៀនសូត្រទៅអនាគតបើមានលទ្ធភាព ។ ចំពោះមិត្តភក្តិចាស់របស់ ធវ័ន្ត ឈ្មោះ ផល ហេង (សព្វថ្ងៃនៅដើរលេងយប់ផឹកស៊ីមិនចូលផ្ទះ សំឡុតគំរាម ម្តាយយកប្រាក់)រស់នៅក្នុងភូមិជាមួយ ក៏បានប្រាប់ឲ្យដឹងថា ធវ័ន្ត មិនដែលដើរចូលក្រុមរបស់ខ្លួនឡើយ ដោយគេរវល់ការងាររៀនជំនាញ ។

*ធវន្ត គឺជាឧទាហរណ៍គំរូមួយក្នុងសហគមន៍ ដែលបានផ្លាស់ប្តូរជីវិតពីក្មេងទំនើង ផឹកស៊ីដើរលេង វាយតប់គ្នា មិនចូលផ្ទះ មកជាក្មេងយកចិត្តទុកដាក់រៀនសូត្រជំនាញ ចេះជួយការងារផ្ទះ និងមានអាកប្បកិរិយាល្អឡើងវិញ អាចក្លាយជាក្មេងគំរូសម្រាប់ក្មេងទំនើងដ៏ទៃទៀត ក្នុងសហគមន៍ ។ ការផ្លាស់ប្តូរនេះ បានបង្ហាញឲ្យឃើញថា កម្មវិធី ទ.ប.ស.ស ដែលបានទទួលមូលនិធិពីគម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា ពិតជាបាននាំមកនូវផលប្រយោជន៍វិជ្ជមានដល់សហគមន៍ ដោយបានរួមចំណែកក្នុងការកាត់បន្ថយនូវឥរិយាបថដែលអាចពាក់ព័ន្ធទៅនឹងបទល្មើស ឬរងគ្រោះដោយសារបទល្មើស ក្នុងស្រទាប់យុវវ័យ និងអនីតិជន ។ គេអាចប្រទះឃើញករណីស្រដៀងគ្នានេះជាច្រើនទៀត នៅតាមកម្មវិធីជំនួយ ទ.ប.ស.ស ដែលបានទទួលមូលនិធិពីគម្រោជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា នៅតាមបណ្តារខេត្តដៃគូផ្សេងៗ៕* ***ដោយ ដួង វណ្ណា***

| | |
|---|---|
| **ស៊ី.ស៊ី.ចេប/ផ្នែក៖**<br>*ទប់ស្កាត់បទល្មើស និងសុវត្ថិភាពសហគមន៍*<br>**បុគ្គលបំពេញទំរង់បែបបទ៖**<br>*ឈ្មោះ ៖ ដួង វណ្ណា*<br>*តួនាទី ៖ អនុប្រធានក្រុម*<br>(*ទទួលបន្ទុកការងារ ត្រួតពិនិត្យ*<br>*និងវាយតម្លៃ*) | **កាលបរិច្ឆេទ៖** *ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១១*<br>**អ្នកដែលត្រូវបានសម្ភាសន៍៖**<br>*ឈ្មោះ ៖ ធន ធវន្ត អាយុ៖ ២១ ឆ្នាំ*<br>*ភេទ៖ ប្រុស*<br>*ភូមិ៖ អូរគ្រៀត ឃុំ៖ គារ ស្រុក៖*<br>*មោងឫស្សី ខេត្ត៖ បាត់ដំបង* |

# កិច្ចព្រមព្រៀង

ខ្ញុំបាទ ~~នាងខ្ញុំ~~ឈ្មោះ ឆាន ឆារិទ្ធ ជាប្រជាជនរស់នៅភូមិ ស្វាយព្រៀង ឃុំ គគរ ស្រុក មោងឫស្សី ខេត្ត បាត់ដំបង សូមជានាអះអាងថា ខ្ញុំបាទ ~~នាងខ្ញុំ~~មិនមានជំទាស់ទៅនឹងការចុះផ្សព្វផ្សាយពត៌មាន អំពីជីវប្រវត្តិរបស់ខ្ញុំបាទ នាងខ្ញុំ ទាក់ទងនឹងព្រឹត្តិការណ៍មុន ឬក្រោយពីការគាំទ្ររបស់គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា (CCJAP) និងព័ត៌មានដូចដែលខ្ញុំបាទ នាងខ្ញុំបានចូលរួមសម្ភាសន៍ផ្តល់ព័ត៌មាននាថ្ងៃទី 7 ខែ មេសា ឆ្នាំ២០១១ឡើយ។

ដើម្បីជាសក្ខីភាពចំពោះកិច្ចព្រមព្រៀងនេះខ្ញុំបាទ ~~នាងខ្ញុំ~~សូមផ្តិតមេដៃបញ្ជាក់ដូចខាងក្រោម ។

ថ្ងៃទី 7 ខែ មេសា ឆ្នាំ២០១១

ស្នាមមេដៃ